# ដឹងក្តី

## ១- ព័ត៌មានទូទៅ

*ភាសា ពាក្យ* ដែលខ្មែរប្រើប្រាស់តាំងពីបុរាណមកទល់គ្នានឹងបច្ចុប្បន្នយើងសង្កេតឃើញថាបានវិវត្តន៍ និងឆ្លងកាត់ប្រវត្តិសាស្ត្រយ៉ាងច្រើនដំណាក់កាលកន្លងមក។ ដូច្នេះធ្វើឱ្យយើងជាមនុស្សរស់នៅក្នុងសង្គមបច្ចុប្បន្នយល់ពី *ភាសា ពាក្យ* ទាំងនោះអាចល្អៀងខុសពីន័យដើម ហើយបង្កើតជាន័យទីពីររបស់*ភាសា ពាក្យ* នោះផងដែរ។ ស្ថិតក្នុងបញ្ហានេះ ពាក្យ «**ដឹងក្តី**» ជាទូទៅគេសម្គាល់ទៅលើមនុស្សដែលស្ថិតក្នុងដំណាក់កាលវ័យអាចចងចាំរឿងរ៉ាវ ហេតុការណ៍ ព្រឹត្តិការណ៍ អាចបែងចែកខុសត្រូវ ដឹងហេតុផល ល្អអាក្រក់ គាប់គួរមិនគាប់គួរជាដើម។ ឧទាហរណ៍ៈ *កាលសម័យ ប៉ុល ពត កូនៗខ្ញុំនៅតូចៗណាស់មិនទាន់ដឹងក្តីនៅឡើយផង។ រឿងនេះមានយូរហើយ តាំងពីខ្ញុំមិនទាន់ដឹងក្តីមកម៉្លេះ*។ ចំពោះន័យរបស់ពាក្យនេះវិញ ប្រហែលជាមានអ្នកដែលយល់ពុំមានច្រើនទេ។ ក្នុងភាសាខ្មែរមានពាក្យពីរផ្សេងគ្នា មានន័យដូចគ្នាក៏មាន(សទិសសូរ) ពាក្យខុសគ្នាតែមានន័យដូចគ្នាក៏មាន (សទិសន័យ)។ ដូចជាពាក្យ *ដឹងក្តី* ន័យរបស់ការពន្យល់កន្លងមកឃើញថាជាការយល់ឃើញម្យ៉ាងតាមន័យពាក្យសព្ទកើតពីការផ្សំគ្នារវាងពាក្យ «**ដឹង + ក្តី**» ន័យថាដឹងសេចក្តីដឹងហេតុការណ៍។ ប៉ុន្តែបើយើងពិចារណាឱ្យវែងឆ្ងាយបន្តិចទៀត ពាក្យនេះមានន័យទាក់ទងវប្បធម៌ខ្មែរជាពិសេសសម័យកណ្តាល។

## ២- តើពាក្យ ដឹងក្តី មានន័យទំនាក់ទំនងនឹងវប្បធម៌ខ្មែរដូចម្តេច ?

ដំបូងយើងពិចារណាន័យរបស់ពាក្យនេះដោយញែកពាក្យជាពីរគឺ «**ដឹង**»និង«**ក្តី**»។ ពាក្យ«**ដឹង**» មានន័យថាការយល់ជ្រាបពីដំណើរហេតុការណ៍ សេចក្តីរឿងរ៉ាវណាមួយ។ រីឯពាក្យ «**ក្តី**» វិញតោងយើងពិចារណាឱ្យបានល្អិតល្អន់បន្តិចព្រោះពាក្យនេះមានតាំងពីបុរាណមក ហើយន័យក៏ខុសគ្នា។ តាមវចនានុក្រមខ្មែរបានពន្យល់ពាក្យ «**ក្តី**» មានន័យ

អត្ថបទដោយៈ រឹម ទិត្យបញ្ញា

ច្រើនគួរឱ្យចាប់អារម្មណ៍។ ពាក្យ **«ក្ដី»** ជាពាក្យបុរាណសំដៅដល់វត្តអារាមជាទីនៅនៃភិក្ខុ-សាមណេរគង់ស្នាក់អាស្រ័យនៅ ដើម្បីសិក្សារៀនសូត្រធម៌អាថ៌ គម្ពីរ សាស្ត្រា ក្បួន ច្បាប់ បំណិន ចំណេះវិជ្ជាផ្សេងៗ។ បើគេនិយាយថាឱ្យកូនទៅនៅក្ដី គឺមានន័យថាឱ្យកូននៅវត្ត ដោយមានភិក្ខុសង្ឃជាគ្រូបង្រៀនឱ្យបានចេះដឹងសេចក្ដីខុសត្រូវ។ ពាក្យទីពីរ **«ក្ដី»** មួយទៀតក្លាយពីពាក្យ គតិ ជាពាក្យសំស្ក្រឹត-បាលី មានន័យថា ដំណើរការណ៍ ដំណើរហេតុការណ៍។ *ឧទាហរណ៍ អធិករណ៍ដែលប្ដឹងផ្ដល់គ្នារហូតដល់ទីតុលាការវិនិច្ឆ័យ។ កុំឈ្លោះនឹងស្រី កុំក្ដីនឹងសង្ឃ។ តុលាការជម្រះក្ដី ។* ពាក្យទីបី **«ក្ដី»** ជានិបាតសព្ទប្រាប់សេចក្ដីថា ឬក៏ដោយ ទាំងនេះទាំងនោះ ឬនេះក៏បាន នោះក៏បាន។ *ឧទាហរណ៍ ខ្ញុំក្ដី អ្នកក្ដី; ទោះគេមកក្ដី គេពុំមកក្ដី។*[១]

លោកគ្រូ អាំង ជូលាន ពន្យល់ថាពាក្យ **ក្ដី** មានន័យច្រើន។ តាមការពិចារណារបស់លោកគ្រូ ពាក្យ **«ក្ដី»** ដែលក្លាយពីពាក្យ គតិ នៅតែមានគេប្រើប្រាស់រហូតមកដល់សព្វថ្ងៃ ហើយបង្រួមន័យនៅត្រឹមន័យថា ដំណើរ ដូចជាមានពាក្យថា គតិបណ្ឌិត កាកគតិ។ តែពាក្យ **«ក្ដី»** ក្នុងន័យវែងឆ្ងាយដែលទាក់ទងនឹងវប្បធម៌នោះ ក៏នៅតែប្រើដដែលពុំបាត់បង់ទៅណាទេ។ ពាក្យ **«ក្ដី»** នោះក្លាយមកពីពាក្យ **«កុដិ»** ដែលប្រើក្នុងសិលាចារឹកបុរាណ។ ដូចមានឈ្មោះបុរាណដ្ឋានជាលំនៅបព្វជិតដូចជា៖ បន្ទាយក្ដី កំពង់ក្ដី ក្ដីតាកុយ ក្ដីតាចិន។ នៅសម័យបុរាណពាក្យ **«ក្ដី»** សំដៅលើសំណង់អាគាររាប់តាំងពីជម្រកនៃអ្នកធ្វើបដិបត្តិធម៌ឡើងទៅដែលប្រើជាញឹកញាប់នោះ គឺសំដៅទៅលើតួប៉មប្រាសាទដូចបញ្ជាក់នៅក្នុងសិលាចារឹកប្រាសាទព្រះគោហៅថា**«វ្រះកុដិ»** គឺ **«ព្រះកុដិ»**។ ពាក្យនេះមាននៅក្នុងសិលាចារឹក ហើយសរសេរខុសប្លែកគ្នាខ្លះដូចជា៖ **វ្រះកុដី វ្រះកុតិ វ្រះកុត្យិ កុឌ្យ កូដ្យ**។[២] លុះចំណេរក្រោយមកពាក្យ **«វ្រះកុដិ»** ហៅសំដៅទៅលើតួប្រាសាទទាំងមូលតែម្ដង ដូចនៅក្នុងករណី

---

[១] ពុទ្ធសាសនបណ្ឌិត្យ, វចនានុក្រមខ្មែរបោះពុម្ពលើកទី៥, ភ្នំពេញ, ឆ្នាំ១៩៦៧, ទំ៦៦

[២] សូមអាន៖ អាំង ជូលាន, កម្រងអត្ថបទស្រាវជ្រាវវប្បធម៌ខ្មែរលេខ២, សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ, ឆ្នាំ២០២១

អត្ថបទដោយ៖ រឹម ទិត្យបញ្ញា

ប្រាសាទបាយ័ន្ត។ មានពាក្យ **«ក្តី»** មួយទៀតមានន័យថា វត្ត កុដិ ជាលំនៅរបស់អ្នកបួស អ្នកបដិបត្តិធម៌នៅវត្តមានព្រះសង្ឃក្មេង។[៣]

នៅក្នុងសៀវភៅប្រវត្តិការអប់រំនៅកម្ពុជារបស់លោកគ្រូ **យង់ ធី** និងលោកគ្រូ **ស៊ិន សំណាង** បានពន្យល់ខ្លីថា **ក្តី = កុដិ** ។ ដូច្នេះហើយបានជាពាក្យដឹងក្តីនេះប្រើសម្រាប់ហៅអ្នកដែលបានរៀនសូត្រនៅវត្តដូចជាព្រះសង្ឃ ក្មេងវត្ត ពេលចេញមកវិញគេហៅអ្នកដឹងក្តី ព្រោះបានទទួលការចេះដឹងអាស្រ័យការរស់នៅក្នុងវត្តជាមួយព្រះសង្ឃ។[៤]

តាមការពន្យល់ក្នុងវចនានុក្រមខ្មែរពាក្យ **«ក្តី»** ក្នុងន័យទីមួយ និងទិន្នន័យទាំងពីរខាងលើ **«ក្តី»** មានន័យថា **«វត្ត»** ដូចគ្នាព្រោះជាកន្លែងសម្រាប់អ្នកបួស បព្វជិត អាស្រ័យនៅដែលមានតួនាទីសម្រាប់បព្វជិតព្រះពុទ្ធសាសនាដូចនឹងប្រាសាទបុរាណ។ ក្រៅពីនេះសូម្បីតែនៅក្នុងសាស្ត្រាខ្មែរសម័យកណ្តាល ជាពិសេសនៅពល់ផ្នែកផ្តើមសាស្ត្រាទេសន៍កាលណាគេនិយាយអំពីវត្តជេតពន ដែលជាអារាមមួយកន្លែងដែលព្រះពុទ្ធគង់នៅយូរជាងគេនោះគេតែងសរសេរភ្ជាប់បន្ថែមថា **ស្រីជេ្យជេតុពុនសូគុនកុត្តីស្រៀមហារិហ៊ា** មានន័យថាវត្តជេតពនជាអារាមធំដែលមានសិរីជ័យដ៏ក្រអូបប្រសើរ។ ដូច្នេះពាក្យ ថា **កុត្តី** ត្រូវនឹងពាក្យ **កុដី** ដែលមានន័យថាវត្ត ព្រោះថានៅក្នុងសង្គមខ្មែរនាសតវត្សរ៍ទី១៦ មានសង្ឃសព្វមួយគឺ **អាយកុដិ**។[៥] ដូចគ្នានេះដែរសាស្ត្រាល្បែងសតវត្សរ៍ទី១៩យើងឃើញមានប្រើពាក្យថា **អាយក្តី** សម្រាប់អ្នកបួសជាឥសី ឬតាបស ប្រើនិយាយជំនួសឈ្មោះខ្លួនឯងនៅពេលនិយាយទៅរកគ្រហស្ថជំនួសពាក្យថា **អាត្មា** មានន័យថាជាអ្នកដឹងសេចក្តីខុសត្រូវរាក់ជ្រៅបាន ដឹងកិច្ចការក្នុងក្រៅ។ ឧទាហរណ៍ក្នុងល្បះមួយនៃរឿងរាជកុលៈ *អ្នកមកហេតុដូចម្តេច ប្រើនឬតិចអស់គ្នីគ្នា ចូលអ្នកប្រាប់អាយក្តី នឹងបានដឹងកាលនោះហោង។* ប៉ុន្តែនៅក្នុងវចនានុក្រមខ្មែរសរសេរថា អាចក្តី *ឧទាហរណ៍អាចក្តីបួសបាន ១០ វស្សា*

---

[៣] *សូមអានៈអាំង ជូលាន, រស់នៅក្តីណា, កម្រងអត្ថបទក្នុងបណ្តាញព័ត៌មានវប្បធម៌ខ្មែរ, លេខ៩, យសោធរ, ភ្នំពេញ*

[៤] *សូមអានៈយង់ ធី, ស៊ិន សំណាង, ប្រវត្តិនៃការអប់រំនៅកម្ពុជា, ភ្នំពេញ, ១៩៩៩*

[៥] *សូមអានៈ អាំង ជូលាន, កម្រងអត្ថបទស្រាវជ្រាវវប្បធម៌ខ្មែរលេខ៤, សាកលវិទ្យាល័យភូមិវិចិត្រសិល្បៈ, ឆ្នាំ២០២១*

*អត្ថបទដោយៈ រឹម ទិត្យបញ្ញា*

AMS អរិយធម៌ខ្មែរ KHMER CIVILIZATION

*ហើយ ប៉ុន្តែអាចក្តីមិនចេះទេស្នាទេ ចេះតែសូត្រធម៌ សម័យសព្វថ្ងៃនេះមិនសូវប្រើ, ប្រើតែពាក្យ អាត្មា ជាធម្មតា ។*

*សរុបមកពាក្យ **«ដឹងក្តី»** ជាពាក្យដែលមានតាំងពីយូរណាស់មកហើយដែលយើងឃើញមានក្នុងសិលាចារឹកជាច្រើនដែលក្លាយមកពីដើមពាក្យ «**កុដិ**» ។ ឯពាក្យ «**កុដិ**» នេះក៏ក្លាយទៅជាពាក្យ «**ក្តី**» មានន័យថាវត្ត។ ជាពិសេសពាក្យនេះយើងចាត់ទុកថាជាសង្ឃសព្ទសម្រាប់ព្រះសង្ឃប្រើ តួយ៉ាងដូចជាពាក្យ **អាយកុដិ** ក្លាយជា **អាយក្តី** នៅក្នុងសាស្ត្រាល្បែងសម័យកណ្តាលសម្រាប់អ្នកបួសនិយាយជាមួយគ្រហស្ថ។ ពាក្យនេះដែរមានន័យទូលំទូលាយទាក់ទងនឹងវប្បធម៌ខ្មែរ អក្សរសាស្ត្រខ្មែរ អក្សរសិល្ប៍ខ្មែរ។ សម្រាប់សម័យទំនើបពាក្យថា **«ដឹងក្តី»** សំដៅទៅលើអ្នកដែលធ្លាប់បួសរៀនចេះដឹងធ្លាប់បួសរៀននៅវត្ត ទើបចាស់ទុំតែងនិយាយថា៖ **អ្នកដែលបួសរៀននៅវត្តសុទ្ធតែជាអ្នកដឹងក្តី**។ ន័យនេះផងដែរក៏មិនខុសពីពាក្យ **អន្ទិត** សម្រាប់ហៅអ្នកសឹកពីបួសនោះទេ៕*

*អត្ថបទដោយ៖ រឹម ទិត្យបញ្ញា*

# ឯកសារពិគ្រោះ

ឃីង ហុក ឌី

២០០៣, មាលីបទអក្សរសិល្ប៍ខ្មែរសតវត្សទី១៩, ភ្នំពេញ

ពុទ្ធសាសនបណ្ឌិត្យ

១៩៦៧, វចនានុក្រមខ្មែរ, បោះពុម្ពលើកទី៥, ភ្នំពេញ

យង់ ធី, ស៊ន សំណាង

ប្រវត្តិនៃការអប់រំនៅកម្ពុជា, ភ្នំពេញ, ១៩៩៩

អាំង ជូលាន

២០១៣-២០១៤, រស់នៅក្ដីណា, កម្រងអត្ថបទក្នុងបណ្ដាញព័ត៌មានវប្បធម៌ខ្មែរ, លេខ៩, យសោធរ, ភ្នំពេញ

២០២១, ក្ដី, កម្រងអត្ថបទស្រាវជ្រាវវប្បធម៌ខ្មែរលេខ២, សាកលវិទ្យាល័យភូមិវិចិត្រសិល្បៈ, ភ្នំពេញ

flickr

https://www.flickr.com/photos/seasiagroup/6244087989/in/photostream

Internet Archive

Buddhist Digital Resource Center Khmer Manuscripts : Free Texts : Free Download, Borrow and Streaming : Internet Archive

## បញ្ជីរូបភាព



ព្រះកុដិ



សំណោផ្តិតសិលាចារឹកប្រាសាទព្រះគោ K.713b

ប្រភពរូប៖https://www.flickr.com/photos/seasiagroup/6244087989/in/photostream



ស្រីជ្យេជេតុពុន សូគុនកុត្តីស្រ្យមហាវិហ៊ាទំ្ទឪតំប្រសើរ

ប្រភពរូប៖ Buddhist Digital Resource Center Khmer Manuscripts : Free Texts : Free Download, Borrow and Streaming : Internet Archive

អត្ថបទដោយ៖ រឹម ទិត្យបញ្ញា



សកម្មភាពបង្រៀនសម័យបុរាណប្រភពរូបៈសៀវភៅប្រវត្តិការអប់រំនៅកម្ពុជា



អច្ចុតមហាឥសីនិយាយជាមួយជូជក់

អរិយធម៌ខ្មែរ
KHMER CIVILIZATION

អត្ថបទដោយៈ រឹម ទិត្យបញ្ញា